


# កំហុសខ្ញុំ

Belgian Development Cooperation

Let's Read
The Asia Foundation

ពាក្យថ្មីនៅក្នុងសៀវភៅនេះ៖ កំហុស ការពារ គុម្ពោត ងងឹត ចឹក ជឿ ជៀសវាង បុណ្យ បន្លាច ពស់ ព្រៃ រន្ធ វិធី



ឆើត ណាល់ និងតីរៀនថ្នាក់ជាមួយគ្នា ។



ឆើតជាកុមារដែលចូលចិត្តបន្លាចគេ ។ តី និងណាល់ខ្លាចពស់ ។



ថ្ងៃមួយ ពេលកុមារទាំងបីចេញពីសាលារៀន ។ ឆើតស្រែក៖ ” ពស់! ពស់!” ។



តី និងណាល់ខ្លាច ហើយរត់យ៉ាងលឿន ។ ឆើតពោល៖ ”ខ្ញុំនិយាយលេងទេ” ។



ពីរថ្ងៃក្រោយមក ឆើត ណាល់ និងតីបានទៅលេងបុណ្យក្នុងភូមិ
។





ឆើតក៏ស្រែក៖ ”ពស់! ពស់!” ។ តី និងណាល់ខ្លាច ហើយរត់យ៉ាងលឿន ។ ឆើតពោល៖ ”ខ្ញុំនិយាយលេងទេ ពស់ជ័រទេតើ!” ។



ណាល់និយាយ៖ ″ឆើតឯងកុំលេងអ៊ីចឹងទៀត ខ្ញុំខ្លាចណាស់!″ ។ ឆើតបានសុំទោស តី និងណាល់ ។ ណាល់និយាយ៖ ″តោះ! យើងមើលគេរាំ″ ។





បីថ្ងៃក្រោយមក ឆើត តី និងណាល់បានទៅសាលារៀន។ ឆើត ស្រែក៖ ”ពស់! ពស់! ជួយផង! ជួយផង!” ។



ណាល់និយាយ៖ ”ឯងកុំនិយាយបន្លាចយើងអី! យើងមិនជឿឯងទេ” ។



ឆើតស្រែក៖ ”ជួយផង! ជួយផង! ពស់ចឹកខ្ញុំមែន!” ។



នេះគឺជាពេលដែលតី និងណាល់ចេញពីរៀន ។ ណាល់សួរ៖ ”
តី! ឯណាឆើត?” ណាល់សួរបញ្ជាក់៖ ”តី! តើពស់ពិតជាចឹក
ឆើតមែនទេ?”



តី និងណាល់បានទៅផ្ទះឆើត ។



ណាល់សួរ៖ ”ពស់ចឹកឯងមែនឬឆើត?” ឆើតឆ្លើយ៖ ”មែន!” ។ យើងសុំទោស យើងគិតថាឯងនិយាយលេងថាមានពស់ ។ ឆើតឆ្លើយ៖ ”មិនអីទេ នេះជាកំហុសរបស់ខ្ញុំ” ។



ការពារកុំឱ្យពស់ចឹក ជៀសវាងដើរកាត់ស្មៅ ឬគុម្ពោតព្រៃ ព្រោះជាកន្លែងដែលពស់រស់នៅ ។ ជៀសវាងដើរកាត់ស្មៅ ឬព្រៃពេលងងឹត ព្រោះជាពេលដែលពស់ស្វែងរកចំណី ។ ជៀសវាងលូករន្ធ ព្រោះអាចមានពស់ ។ កុំលេងពស់ ។

# Brought to you by

The Asia Foundation

Let’s Read is an initiative of The Asia Foundation’s Books for Asia program that fosters young readers in Asia and the Pacific.
booksforasia.org
To read more books like this and get further information about this book, visit letsreadasia.org

**Original Story**
*កំហុសខ្ញុំ*, Author: Belgian Development Cooperation. Published by Ministry of Education, Youth, and Sports of Cambodia, © Ministry of Education, Youth, and Sports of Cambodia.

Translations: © The Asia Foundation, 2018.